# ជំនួយឧបត្ថម្ភដល់ការសិក្សាថ្នាក់បរិញ្ញាបត្រ
# ២០១៩-២០២០
# ការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក

## បទបញ្ញត្តិ

**ការប្រកាសជ្រើសរើសបេក្ខភាពថ្នាក់តំបន់ចាប់ពីថ្ងៃទី ១៥ ខែកញ្ញា ដល់ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៩ សំរាប់និស្សិតវៀតណាម ឡាវ និងវ៉ាន់ណាទូ និងរហូតដល់ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ២០១៩ សំរាប់និស្សិតកម្ពុជា**

### ១. គោលបំណង

ការប្រកាសជ្រើសរើសនេះសំរាប់តែនិស្សិតថ្នាក់បរិញ្ញាបត្រដែលបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលជាភាសាបារាំងនៅតាមសាកលវិទ្យាល័យជាសមាជិករបស់ AUF ក្នុងតំបន់អាស៊ីអាគ្នេយ៍ (កម្ពុជា ឡាវ វៀតណាម)។ ជំនួយឧបត្ថម្ភការសិក្សានេះផ្តល់ជូននិស្សិតដោយផ្តោតលើកត្តាសង្គម ក្នុងការជួយដល់និស្សិតក្រីក្រដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុក្នុងការសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលជាភាសាបារាំង ។
បញ្ជីឈ្មោះការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាភាសាបារាំងអាចរកមើលបានតាមរយៈអាស័យដ្ឋាន៖
https://drive.google.com/file/d/1qKhij0FFofsxhXETDFTvesrZBqC7XECf/view

### ២. លក្ខណ្ឌសំរាប់ការដាក់បេក្ខភាព

ជំនួយឧបត្ថម្ភការសិក្សាគឺជាជំនួយហិរញ្ញវត្ថុផ្តោតទៅលើកត្តាសង្គមដោយផ្តល់ជូនដល់និស្សិតក្រីក្រដែលកំពុងសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលជាភាសាបារាំងក្នុងប្រទេសរបស់ខ្លួន។

**ការប្រកាសជ្រើសរើសបេក្ខភាពសំរាប់ឆ្នាំសិក្សា ២០១៩-២០២០ នេះផ្តល់ជូនដល់តែនិស្សិតកម្ពុជា ឡាវ វៀតណាម រៀនថ្នាក់បរិញ្ញាបត្រជាភាសាបារាំងដែលស្ថិតនៅក្រោមគំរោងជំនួយជ្រោមជ្រែងរបស់ AUF តែប៉ុណ្ណោះ ។**

ជំនួយឧបត្ថម្ភការសិក្សាប្រចាំឆ្នាំត្រូវអនុម័តយល់ព្រមដោយគណៈកម្មាការជំនាញថ្នាក់តំបន់ (CRE) តាមរយៈសំណុំលិខិតរបស់បេក្ខជន ជាមួយនឹងទឹកប្រាក់ឧបត្ថម្ភមានពីរជម្រើស ៖ ជំរើស A **ចំនួន ៣០០ ដុល្លារ** និង ជំរើស B **ចំនួន១៥០ ដុល្លារ**។ ដូច្នេះវាសំខាន់ណាស់ដែលបេក្ខជនត្រូវបញ្ជាក់នៅក្នុងលិខិតបង្ហាញពីគោលបំណង (Lettre de motivation) របស់ខ្លួននូវជម្រើសណាមួយ និងមូលហេតុសមស្របដែលបញ្ជាក់ពីការស្នើរសុំនោះ (ឧទាហរណ៍៖ ការបង់ថ្លៃចុះឈ្មោះចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន)។
ដើម្បីស្នើសុំប្រាក់ឧបត្ថម្ភការសិក្សាបេក្ខជនត្រូវ៖

- ចុះឈ្មោះចូលរៀនឆ្នាំសិក្សា ២០១៩-២០២០ ក្នុងការបណ្តុះបណ្តាលជាភាសាបារាំងនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាជាសមាជិករបស់ AUF
- ផ្តល់ជូនគ្រប់ឯកសារតម្រូវ៖ ប្រវត្តិរូបនៃការសិក្សាសង្ខេប (CV) ព្រឹត្តិប័ត្រពិន្ទុ សញ្ញាប័ត្រ ជាដើម
- ដាក់សំណុំលិខិតបេក្ខភាពបំពេញបានត្រឹមត្រូវនិងទាន់ពេលវេលាកំណត់។

## ៣. ការជ្រើសរើសបេក្ខភាព

<u>និតិវិធី</u> ៖

បេក្ខជនត្រូវបំពេញទំរង់បែបបទស្នើរជំនួយឧបត្ថម្ភសិក្សាតាមអាំងទែណែតបានតាមរយៈគេហទំព័រ (**https://formulaires.auf.org/**) ស្របតាមថេរវេលាដែលបានកំណត់។ បេក្ខជនម្នាក់ៗអាចបំពេញសំណុំលិខិតស្នើរសុំបានតែមួយគត់។

ការិយាល័យថ្នាក់តំបន់របស់ AUF ធ្វើការវាយតម្លៃលើសំណុំលិខិតបេក្ខភាព បន្ទាប់ពីការពិនិត្យលើភាពត្រឹមត្រូវនៃសំណុំលិខិតទាំងនោះ ។ សំណុំលិខិតរបស់បេក្ខជនត្រូវធ្វើការជ្រើសរើសដោយផ្អែកលើលក្ខខណ្ឌសង្គមនិងត្រូវដាក់សុំយោបល់ពីប្រធានទទួលបន្ទុកការបណ្តុះបណ្តាលប្រូង់កូហ្វូននៃគ្រឹះស្ថានសិក្សារបស់បេក្ខជន និងស្របទៅតាមកញ្ចប់ថវិការនៃគម្រោងដែលមាន។ សំណុំលិខិតដែលដាក់មិនត្រូវបានប្រគល់ត្រឡប់ឲ្យបេក្ខជនវិញឡើយ។

លក្ខណៈវិនិច្ឆ័យសំខាន់ៗសំរាប់និតិវិធីក្នុងការជ្រើសរើសមានដូចជា ៖

- ស្ថានភាពរបស់សាម៉ីខ្លួន និង គ្រួសាររបស់បេក្ខជន
- គម្លាតឆ្ងាយរវាងលំនៅដ្ឋាន និង គ្រឹះស្ថានសិក្សា
- ក្នុងករណីដែលសំណុំលិខិតមានលក្ខណៈល្អប្រហាក់ប្រហែលគ្នា បេក្ខភាពនារី និង/ឬ អ្នកដែលមានលទ្ធផលសិក្សាល្អនឹងត្រូវទទួលបានបុព្វសិទ្ធិ
- មតិយោបល់របស់ប្រធានទទួលបន្ទុកការបណ្តុះបណ្តាលប្រូង់កូហ្វូននៃគ្រឹះស្ថានសិក្សា។

## ៤. របៀបផ្តល់ជំនួយឧបត្ថម្ភការសិក្សា

ជំនួយឧបត្ថម្ភការសិក្សាផ្តល់ជូនសំរាប់តែរយៈពេលមួយឆ្នាំសិក្សា។ បេក្ខជនត្រូវធ្វើការស្នើរសុំបន្តជំនួយឧបត្ថម្ភការសិក្សានេះរៀងរាល់ឆ្នាំសិក្សា ។

## ៥. វិធីផ្តល់ជំនួយថវិការរបស់ AUF

ទឹកប្រាក់ឧបត្ថម្ភការសិក្សាផ្តល់ជូនជាពីរដំណាក់កាល សំរាប់និស្សិតរៀននៅក្នុងកម្មវិធីបណ្តុះបណ្តាលជាភាសាបារាំង (នៅរាល់ចុងបញ្ចប់នៃឆមាសនិមួយៗ)។ ជំនួយឧបត្ថម្ភការសិក្សាប្រចាំឆ្នាំត្រូវបានអនុម័តយល់ព្រមតាមរយៈសំណុំលិខិតរបស់បេក្ខជនជាមួយការស្នើរសុំប្រាក់ឧបត្ថម្ភពីរជម្រើស ៖ ជំរើស A ចំនួន ៣០០ ដុល្លារ និង ជំរើស B ចំនួន ១៥០ ដុល្លារ ។

ក្នុងករណីដែលគ្រឹះស្ថានសិក្សាជូនដំណឹងដល់ AUF ពីការបញ្ឈប់ការសិក្សាមុនពេលកំនត់របស់បេក្ខជន ឬក៏និស្សិតមិនគោរពតាមលក្ខណ្ឌនៃការផ្តល់ជំនួយហិរញ្ញវត្ថុ នោះ AUF អាចព្យួរ ឬលុបចោលការផ្តល់ប្រាក់ឧបត្ថម្ភបន្ទាប់ ។

## ៦. កាតព្វកិច្ចរបស់គ្រឹះស្ថានសិក្សារបស់បេក្ខជន

**គ្រឹះស្ថានសិក្សារបស់និស្សិតដែលទទួលជំនួយឧបត្ថម្ភការសិក្សាសូមសន្យាថា ៖**

- ឲ្យនិស្សិតគោរពនូវបទបញ្ញត្តិដែលបានចែងខាងលើនេះ
- ជូនដំណឹងយ៉ាងឆាប់រហ័សបំផុតដល់ AUF គ្រប់ការបញ្ឈប់ការសិក្សាមុនពេលកំនត់របស់និស្សិតដែលទទួលបានជំនួយឧបត្ថម្ភការសិក្សា
- ឲ្យនិស្សិតគោរពនូវបទបញ្ញត្តិជាធរមានផ្សេងៗរបស់គ្រឹះស្ថានឧត្តមសិក្សា។

## ៧. ប្រតិទិន

**សំរាប់បេក្ខជនវៀតណាម ឡាវ និងវ៉ាន់ណាទូ**

- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ ៖ ចាប់ផ្តើមការផ្សព្វផ្សាយការប្រកាសជ្រើសរើសបេក្ខភាព
- ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ ៖ បិទបញ្ចប់ការប្រកាសជ្រើសរើសបេក្ខភាព
- ខែវិច្ឆិកា ឆ្នាំ២០១៩ ៖ ប្រកាសលទ្ធផលនៃការជ្រើសរើសបេក្ខភាព (បញ្ជីឈ្មោះសំរេចចុងក្រោយ)

**សំរាប់បេក្ខជនកម្ពុជា**

- ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ ៖ ចាប់ផ្តើមការផ្សព្វផ្សាយការប្រកាសជ្រើសរើសបេក្ខភាព
- ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ៖ បិទបញ្ចប់ការប្រកាសជ្រើសរើសបេក្ខភាព
- ខែធ្នូ ឆ្នាំ២០១៩ ៖ ប្រកាសលទ្ធផលនៃការជ្រើសរើសបេក្ខភាព (បញ្ជីឈ្មោះសំរេចចុងក្រោយ)

## ៨. ការរៀបចំសំណុំលិខិតបេក្ខភាព

សំណុំលិខិតបេក្ខភាពត្រូវតែបំពេញតាមអ៊ិនទែណែតតាមរយៈអាស័យដ្ឋាន (https://formulaires.auf.org/) និងត្រូវគោរពថេរវេលាដែលបានកំណត់ ។

**ដើម្បីឱ្យមានលក្ខណៈពេញលេញ និងត្រឹមត្រូវ សំណុំលិខិតបេក្ខភាពត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនមានដូចតទៅ (ត្រូវដាក់ភ្ជាប់ជាមួយបែបបទនៃការស្នើរសុំ) ៖**

១. ប្រវត្តិរូបនៃការសិក្សាសង្ខេប (CV) ដែលបានធ្វើបច្ចុប្បន្នភាពមានបិទរូបថតមួយសន្លឹក

២. ច្បាប់ថតចម្លងព្រឹត្តិប័ត្រពិន្ទុនៃឆ្នាំសិក្សាកន្លងមក (សំរាប់បេក្ខជនរៀនចាប់ពីឆ្នាំទី២ ឡើងទៅ)

៣. ច្បាប់ថតចម្លងពិន្ទុប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (សំរាប់បេក្ខជនកម្ពុជានិងឡាវដែលរៀននៅឆ្នាំទី១)

៤. លិខិតបញ្ជាក់ពីស្ថានភាពក្រីក្ររបស់គ្រួសារបេក្ខជនចេញដោយអាជ្ញាធរមានសមត្ថកិច្ចឃុំ-សង្កាត់ដែលគ្រួសារបេក្ខជនស្នាក់នៅ។

**គ្រប់ឯកសារដែលត្រូវភ្ជាប់ជាមួយសំណុំលិខិតបេក្ខភាពទាំងអស់ ត្រូវសរសេរជាភាសាខ្មែរសំរាប់និស្សិតឆ្នាំទី១និង ជាភាសាបារាំងសំរាប់និស្សិតឆ្នាំទី២ឡើងទៅ។**

**អវត្តមានឯកសារណាមួយក្នុងចំណោមឯកសារខាងលើ បេក្ខជនត្រូវធ្លាក់ជាស្វ័យប្រវត្តិ។**

ក្រោយពីបញ្ជាក់ភាពត្រឹមត្រូវលើសំណុំលិខិតបេក្ខភាពក្នុងអំឡុងពេលបំពេញឯកសារតាមអ៊ិនទែណែតរួចហើយ បេក្ខជនមិនអាចបញ្ចូលបន្ថែមឬដកចេញនូវឯកសារឬលិខិតស្នាមណាមួយបានឡើយ បើទោះបីជាការប្រកាសជ្រើសរើសបេក្ខភាពនៅមានសុពលភាពនៅឡើយក៏ដោយ។ រាល់សំណុំលិខិតបេក្ខភាពមិនអនុញ្ញាតិឱ្យផ្ញើតាមប្រអប់ប្រៃណីយ៍ ឬ ទូរសារឡើយ ។
បេក្ខជនម្នាក់ៗអាចធ្វើការស្នើរសុំជំនួយឧបត្ថម្ភការសិក្សាតែមួយដងគត់ក្នុងមួយឆ្នាំសិក្សា ។

## **ឧបសម្ព័ន្ធ ៖** ទំនាក់ទំនងសាកសួរព័ត៌មាននៅ AUF ប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិក និងនៅតាមការិយាល័យប្រចាំប្រទេសនិមួយៗ

### ការិយាល័យប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិកនៅទីក្រុងហាណូយ

*លោកស្រី DINH Thi Hai Yen, អ្នកទទួលបន្ទុកគំពេង*
*អ៊ីម៉ែល : dinh.hai.yen@auf.org*
*ទូរស័ព្ទ : +84 24 38 24 73 82 (ext. 23)*

### ការិយាល័យប្រចាំនៅទីក្រុងហូជីមិញ

*លោក NGUYEN Tan Dai, ប្រធាន CNF*
*អ៊ីម៉ែល : nguyen.tan.dai@auf.org*
*ទូរស័ព្ទ : (+ 84) 28 38 27 95 50 (ext. 104)*

### ការិយាល័យប្រចាំនៅប្រទេសកម្ពុជា

*លោក IM Kravong,ប្រធានការិយាល័យប្រចាំនៅប្រទេសកម្ពុជា*
*អ៊ីម៉ែល : kravong.im@auf.org*
*ទូរស័ព្ទ : (+855) 23 883 135/136 (ext. 12)*

### ការិយាល័យប្រចាំនៅប្រទេសឡាវ

*លោក Antoine BLOMQVIST, ប្រធានការិយាល័យប្រចាំនៅប្រទេសឡាវ*
*អ៊ីម៉ែល : antoine.blomqvist@auf.org*
*Tél : +856 21 77 18 00 | + 856 20 28 035 193 - 77 713 130*

### ការិយាល័យប្រចាំនៅប្រទេសវ៉ាន់ណាទូ

*លោក Chandra MAISONNIER, ប្រធានការិយាល័យនិងCNF នៅទីក្រុងព័រវីឡា*
*អ៊ីម៉ែល : chandra.maisonnier@auf.org*
*Tél : +678 24264*